អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១

# សេចក្ដីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងបដិសេធការសុំនៅក្រៅឃុំរបស់ នួន ជា, ខៀវ សំផន និង អៀង ធិរិទ្ធ

នៅក្នុងសេចក្ដីសម្រេចថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបដិសេធសំណើរបស់ក្រុមមេធាវីការពារក្ដី ដែលសុំឲ្យមានការដោះលែងជនត្រូវចោទ នួន ជា, ខៀវ សំផន និង អៀង ធិរិទ្ធ ឲ្យនៅក្រៅឃុំ។

នៅក្នុងសេចក្ដីសម្រេចមួយដែលចេញកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញបញ្ជាដោយពុំមានសំអាងហេតុ ឲ្យបន្តឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នរហូតដល់ពេលមានការជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីប្រកាសអំពីមូលហេតុនៃការធ្វើសេចក្ដីសម្រេចចិត្តនោះ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។ បន្ទាប់ពីមានបញ្ជារបស់អង្គបុរេជំនុំជម្រះ ជនត្រូវចោទបានដាក់ពាក្យបណ្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង ស្នើសុំការដោះលែងឲ្យនៅក្រៅឃុំ។ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការផ្ទាល់មាត់ទៅលើពាក្យសុំដោះលែងនៅក្រៅឃុំ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១។

នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ភាពយឺតយ៉ាវក្នុងការចេញសំអាងហេតុពាក់ព័ន្ធនឹងការបន្តឃុំខ្លួនជនត្រូវចោទ បានរំលោភលើសិទ្ធរបស់ជនត្រូវចោទ ក៏ប៉ុន្តែតាមធម្មតាការរំលោភសិទ្ធបែបនេះនឹងត្រូវបានដោះស្រាយនៅចុងបញ្ចប់នៃដំណើរការកាត់សេចក្ដី។ ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការបន្តឃុំខ្លួនជនត្រូវចោទគឺមានសារសំខាន់ក្នុងការធានាឲ្យប្រាកដថាជនត្រូវចោទនឹងមានវត្តមាននៅក្នុងអំឡុងពេលកាត់សេចក្ដី។

សេចក្ដីសម្រេចចិត្តរបស់អង្គជំនុំជម្រះសាលាដំបូង អាចទាញយកបានពីគេហទំព័រខាងក្រោម ៖
http://www.eccc.gov.kh/english/cabinet/courtDoc/889/E50_EN.PDF

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: reach.sambath@eccc.gov.kh

**ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ 0២៣
សារអេឡិកត្រូនិក: olsenl@un.org

**ឌីម សុវណ្ណារុំ**
អ្នកនាំពាក្យសាលាក្ដីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨៨ 0៩៤
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: dim.sovannarom@eccc.gov.kh

**យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ៣១៩
សារអេឡិកត្រូនិក: maeday@un.org